

## ជំពូកទី១

# តើខ្ញុំអាចជួយកូនដោយរបៀបណា?

### រឿងរ៉ាវរបស់កុមារីកាមាឡា និង កុមារីរ៉ានី

#### កុមារី កាមាឡា

**កាមាឡា** និងឪពុកម្ដាយនាងឈ្មោះ**ស៊ូមា**និង**អានីល**រស់នៅក្នុងភូមិតូចមួយនៅភាគខាងត្បូងនៃប្រទេសឥណ្ឌា ។ កាលពី**កាមាឡា**នៅតូច ឪពុកម្ដាយនាងបានសម្គាល់ឃើញថា **កាមាឡា**មិនដែលឈោងយកប្រដាប់លេងដែលពួកគាត់ឱ្យទៅនាងឡើយ ។ ពួកគាត់បានយក**កាមាឡា**ទៅជួបវេជ្ជបណ្ឌិតនៅទីក្រុងតូចមួយក្បែរនោះ ដើម្បីឱ្យដឹងប្រាកដថាមានអ្វីខ្លះទាស់ខុស ។




វេជ្ជបណ្ឌិតបានប្រាប់ថា ភ្នែករបស់**កាមាឡា**ងងឹតស្ទើរតែទាំងស្រុងទៅហើយ ។ នាងអាចមើលឃើញចលនាខ្លះៗ និងភាពខុសគ្នារវាងភ្លឺនិងងងឹត ប៉ុន្តែគ្មានអ្វីច្រើនជាងនេះទេ ។ "គំហើញរបស់នាងនឹងមិនល្អឡើងវិញឡើយ" នេះជាប្រសាសន៍វេជ្ជបណ្ឌិត ។ **ស៊ូមា** និង**អានីល**ត្រឡប់មកផ្ទះវិញដោយទុក្ខព្រួយក្នុងចិត្ត ។ "តើរឿងនេះបានកើតឡើងយ៉ាងម៉េចទៅ?" **ស៊ូមា**គិតតែម្នាក់ឯង "នាងជាកូនល្អម្នាក់" ។ **ស៊ូមា**ព្រួយចិត្តអស់ពេលយ៉ាងយូរ ។ **ស៊ូមា** និង**អានីល**បានថែរក្សា**កាមាឡា**តាមវិធីល្អបំផុតដែលពួកគាត់អាចធ្វើបាន ។

ដោយការងាររបស់**អានីល**មិនអាចរកចំណូលបានគ្រប់គ្រាន់ដើម្បីចិញ្ចឹមគ្រួសារ **ស៊ូមា**និងកូនស្រីច្បងពីរនាក់ទៀតបាននាំគ្នារកស៊ីកាត់ដេរខោអាវលក់នៅឯផ្សារ ។ ក្នុងរយៈពេលដែលក្រុមគ្រួសារធ្វើការងារ ពួកគាត់មានពេលតិចណាស់ដើម្បីចំណាយពេលលេងកំសាន្តជាមួយ**កាមាឡា** ម្លោះហើយ**កាមាឡា**ចំណាយពេលស្ទើរពេញមួយថ្ងៃៗអង្គុយម្នាក់ឯងនៅជ្រុងជញ្ជាំង ។ ពេលខ្លះ**ស៊ូមា**ព្រួយចិត្តដែល**កាមាឡា**មិនសូវធ្វើចលនា ឬ បញ្ចេញសម្លេង តែ**ស៊ូមា**ក៏បានធូរក្នុងចិត្តផងដែរដែល**កាមាឡា**ហាក់ដូចជាសប្បាយចិត្តដោយគ្រាន់តែបាននៅជិតពួកគាត់ ។

នៅពេល**កាមាឡា**អាយុបាន 3 ឆ្នាំ នាងចេះនិយាយពាក្យពីរ-បីម៉ាត់តែប៉ុណ្ណោះ ។ នាងហាក់ដូចជាវង្វេងនៅក្នុងស្ថានភាពរបស់នាងស្ទើរគ្រប់ពេលវេលា នាងបានធ្វើចលនាចម្លែកៗដូចជា រុកភ្នែក ឬ ត្រដាងដៃខ្លួនឯងទទះភឹបៗដូចបក្សី ។ នាងមិនអាចហូបចុក ឬ ស្លៀកពាក់ដោយខ្លួនឯងឡើយ ។ **ស៊ូមា**ធ្វើការទាំងនេះជំនួសកូនរហ័សជាងឱ្យ**កាមាឡា**ធ្វើខ្លួនឯង ។




ដោយសារ**កាមាឡា**មិនបានលេងកំសាន្តដូចក្មេងៗអាយុស្រករនាង និងមិនបានរៀនថែទាំខ្លួន ដូច្នេះដៃជើងរបស់នាងមិនបានលូតលាស់មាំមួនឡើយ ។ ខណៈពេលដែលកុមារអាយុស្រករនាងរៀនឈរ និង ដើរ ប៉ុន្តែជើងរបស់**កាមាឡា**នៅទន់ខ្សោយណាស់ ហើយមិនអាចជួយទប់ទម្ងន់ខ្លួនរបស់នាងបានទេ ។

នៅពេល**កាមាឡា**គ្រប់អាយុចូលរៀន ឪពុកម្តាយនាងបានពនាងទៅសាលារៀន ។ ប៉ុន្តែសាលារៀនបានធ្វើឱ្យនាងខ្លាចពីព្រោះនាងមិនដែលទៅណាឆ្ងាយពីផ្ទះ ។ ពីមួយថ្ងៃទៅមួយថ្ងៃ**កាមាឡា**អង្គុយក្នុងថ្នាក់រៀន ហើយគិតតែយំ ។ នៅពេលគ្រូនិយាយរក **កាមាឡា**មិនឆ្លើយតបវិញឡើយ ។

នៅទីបញ្ចប់**ស៊ូមា**និង**អានីល**បានសំរេចចិត្តថា សាលារៀនមិនបានជួយដល់**កាមាឡា** ហើយបានឈប់យកនាងទៅរៀន ។ ប៉ុន្តែពួកគាត់ព្រួយចិត្តចំពោះអនាគតរបស់នាង ។ "បើសិនជានាងមិនអាចទទួលបានការអប់រំ តើនាងនឹងរស់នៅដោយរបៀបណា? តើនរណានឹងថែរក្សានាងនៅពេលដែលពួកយើងស្លាប់ទៅ?"

**កុមារី រ៉ានី**

**រ៉ានី**ជាក្មេងស្រីតូចពិការភ្នែក បានកើតនៅភូមិមួយផ្សេងទៀតក្នុងប្រទេសតណ្ឌាដែរ ។ នៅពេលដែលឪពុកម្តាយនាងឈ្មោះ **ជីវ៉ាន** និង **អារុណា** បានដឹងថាទារិកាតូចរបស់ពួកគាត់ពិការភ្នែក យាយរបស់**រ៉ានី** ឈ្មោះ**បាកា**មានប្រសាសន៍ថា "យើងគួរធ្វើអ្វីៗដែលយើងអាចធ្វើបានដើម្បីបង្រៀនទារិកានេះ ។ ចូរមើលមកម៉ែ ម៉ែបានបាត់បង់គំហើញ 5 ឆ្នាំមកហើយ ។ ម៉ែនៅតែអាចធ្វើកិច្ចការស្ទើរតែទាំងអស់ដែលម៉ែធ្លាប់ធ្វើពីមុន ។ ម៉ែនៅតែអាចទៅយកទឹកពីអណ្តូងមកផ្ទះ និងនៅតែអាចច្របាច់ទឹកដោះពីពពែបាន" ។

"តែមុនពេលម៉ែពិការភ្នែក ម៉ែអាចធ្វើកិច្ចការទាំងនោះរួចទៅហើយ" **ជីវ៉ា**នឆ្លើយតបទៅម្តាយ ។ "តើទារិកាតូចនេះអាចរៀនបែបណាទៅ?

"យើងត្រូវតែជួយជ្រោមជ្រែងនាងឱ្យរៀនសូត្រ" **បាកា** ឆ្លើយតបទៅកូនគាត់ ។ "ដូចដែលម៉ែធ្លាប់រៀនធ្វើអ្វីៗដោយការប្រើប្រាស់សម្លេង និងការស្ទាប ដូច្នេះ**រ៉ានី**ត្រូវតែរៀនអញ្ចឹងដែរ" ។



បុគ្គលិកសុខាភិបាលបានប្រាប់ឱ្យពួកគាត់ផ្តល់ប្រដាប់លេងឱ្យច្រើនឱ្យ**វ៉ានី**លេង ហើយលើកទឹកចិត្តនាងឱ្យចេះប្រើការស្តាប់ ការស្ទាប/ប៉ះ និងហិតក្លិន ដើម្បីជំនួសឱ្យអ្វីៗដែលនាងមិនអាចមើលឃើញ "ហើយនិយាយរកនាងឱ្យបានច្រើន" ប្រសាសន៍របស់បុគ្គលិកសុខាភិបាល ។

ជាពិសេស**បាកា**បានឱ្យ**វ៉ានី**ស្ទាប និងស្តាប់នូវអ្វីៗទាំងឡាយ ។ គាត់បានលេងល្បែងកំសាន្តជាមួយចៅស្រី និងច្រៀងឱ្យចៅស្តាប់ ។ នៅពេល**វ៉ានី**មានអាយុ 2 ឆ្នាំ **បាកា**បង្រៀនចៅឱ្យចេះស្ទាបរកផ្លូវដោយសសៀរតាមជញ្ជាំង និងរបងដូចគាត់ធ្លាប់បានធ្វើអញ្ចឹងដែរ ។ នៅអាយុ 3 ឆ្នាំ **វ៉ានី**អាចរកផ្លូវទៅបង្គន់ និងអណ្តូងទឹកដោយខ្លួនឯង ។




**ជីវ៉ាន អារុណា** និង**បាកា** មិនមានពេលច្រើនសំរាប់អនុវត្តសកម្មភាពពិសេសៗជាមួយ**វ៉ានី**ឡើយ ។ ពួកគាត់ធ្វើការជាច្រើនម៉ោងនៅក្នុងហាងតូចរបស់ខ្លួន ។ ប៉ុន្តែពួកគាត់ជួយ**វ៉ានី**រៀនបំណិនថ្មីៗ ដោយនាំនាងឱ្យធ្វើអ្វីៗជាមួយពួកគាត់ដែលកិច្ចការទាំងនោះពួកគាត់ធ្លាប់ធ្វើរួចហើយដូចជា ទៅផ្សារ ។ សកម្មភាពសាមញ្ញៗប្រចាំថ្ងៃទាំងនេះ បានធ្វើឱ្យមានភាពខុសប្លែកយ៉ាងប្រពៃនៅក្នុងការជួយជ្រោមជ្រែងឱ្យ**វ៉ានី**អភិវឌ្ឍបំណិនជាច្រើន ។

នៅពេល**វ៉ានី**ចាប់ផ្តើមចូលរៀន ក្មេងៗនៅក្នុងភូមិមករកនាងរៀងរាល់ថ្ងៃ ។ នៅពេលអ្នកភូមិបានឃើញពួកគេដើរនៅតាមផ្លូវជាមួយគ្នា អ្នកភូមិពិបាកនិយាយថា ក្មេងណាមួយមើលមិនឃើញ ។

## ការយល់ដឹងរឿងរ៉ាវរបស់កុមារី **កាមាឡា** និងកុមារី **រ៉ានី**

បើសិនជាកូនអ្នកមិនអាចមើលឃើញបានច្បាស់ ឬក៏ពិការភ្នែក អ្នកអាចជួយកូនឱ្យរៀនបំណិនជាច្រើន គឺដូចដែលក្រុមគ្រួសាររបស់**រ៉ានី**បានជួយនាងអញ្ចឹងដែរ ។ ប៉ុន្តែវាជាការសំខាន់ដើម្បីស្វែងយល់ឱ្យដឹងថា ហេតុអ្វី**រ៉ានី**អាចរៀនបំណិនដែលកុមារឯទៀតមានអាយុស្រករនាងកំពុងរៀន ខណៈដែល**កាមាឡា**មិនបានរៀនបំណិនទាំងនោះ ។

ការស្វែងយល់ប្រការនេះ វាជួយឱ្យដឹង :-

- របៀបដែលកុមារអភិវឌ្ឍ (រៀនបំណិនថ្មីៗខណៈដែលគេកំពុងធំលូតលាស់)
- របៀបដែលបញ្ហាគំហើញប៉ះពាល់ដល់ការអភិវឌ្ឍកុមារ

## របៀបដែលកុមារអភិវឌ្ឍ

កុមារគ្រប់រូបអភិវឌ្ឍនៅក្នុងផ្នែកបីធំៗ :- កាយសម្បទា (រាងកាយ), បញ្ញាស្មារតី (ការគិត), និងសង្គម (ការនិយាយស្តី, ការស្តាប់, ការចេះសម្របខ្លួនឱ្យចូលចំណោមនឹងមនុស្សម្នាឯទៀត) ។ នៅក្នុងផ្នែកនីមួយៗ កុមារម្នាក់រៀនបំណិនថ្មីៗមួយជំហានម្តងៗទៅតាមលំដាប់លំដោយច្បាស់លាស់ ។

ឧទាហរណ៍ មុនពេលកុមារចេះដើរ ដំបូងគេត្រូវរៀនគ្រប់គ្រងរាងកាយជាច្រើនប្រភេទ :-



1. ដំបូងគេត្រូវតែចេះងើបក្បាល ហើយលើកដៃ និងជើង



2. បន្ទាប់មកគេអាចប្រើដៃ និងជើងក្នុងការជួយទប់ខ្លួនឯងដើម្បីអង្គុយ។



3. ខណៈពេលកំពុងអង្គុយ គេចាប់ផ្តើមឈោង ផ្អែក និងបត់បង្វិលខ្លួន។ ប្រការនេះជួយគេអភិវឌ្ឍលំនឹង-បំណិនមួយដែលក្នុងពេលឆាប់ៗខាងមុខ គេនឹងត្រូវការសំរាប់ឈរ និងដើរ។



4. បន្ទាប់មក គេប្រឹងតោងឡើងជាស្ថានភាពឈរ។

មុនពេលកុមារអាចនិយាយទៅកាន់មនុស្សម្នាងទៀត គេត្រូវការរៀនប្រាស្រ័យទាក់ទងងាយៗយ៉ាងច្រើន ដូចជា :-




1. ការយល់ដឹងពាក្យ និងសំណើងាយៗ



2. ការប្រើសញ្ញា ឬកាយវិការ




3. និយាយពាក្យងាយៗ




4. ការប្រើប្រយោគខ្លីៗ

បំណិនថ្មីនីមួយៗអភិវឌ្ឍពីលើបំណិនដែលកុមារចេះរួចហើយ និងត្រៀមឱ្យកុមាររៀនបំណិនដទៃទៀតដែលពិបាកជាងមុន។ ដូច្នេះនៅពេលកុមារមិនបានរៀនបំណិនមួយ នេះមានន័យថា គេមិនត្រឹមតែមានបញ្ហាជាមួយបំណិនមួយហ្នឹងឡើយ គឺរួមមានទាំងបំណិនផ្សេងៗទៀតដែលពឹងផ្អែកលើបំណិនដែលគេមិនបានរៀននោះ។

ឧទាហរណ៍ បើសិនជាគេមានបញ្ហាក្នុងការងើបក្បាល នោះកុមារនឹងមានការលំបាករៀនបំណិនដូចជា អង្គុយ ឬ វារ ព្រោះការងើបក្បាលគឺជាបំណិនសំខាន់។ ពេលវេលាចេះតែកន្លងទៅ ការអភិវឌ្ឍរបស់កុមារនឹងយឺតជាងកុមារដទៃដែលមានអាយុស្រករគ្នា។



**បំណិនថ្មីនីមួយៗអភិវឌ្ឍពីលើបំណិនដែលកុមារចេះរួចហើយដូចត្រួតដុំឈើពីលើគ្នាអញ្ចឹងដែរ។**

## របៀបដែលបញ្ញាគំហើញប៉ះពាល់ដល់ការអភិវឌ្ឍកុមារ

នៅពេលកុមារម្នាក់អាចមើលឃើញ ជាទូទៅនាងអភិវឌ្ឍបំណិននានា "តាមធម្មជាតិ" ក្នុងខណៈដែលនាងសម្លឹងមើល ហើយលេងជាមួយមនុស្សម្នា និងវត្ថុទាំងឡាយដែលនាងឃើញនៅជុំវិញខ្លួន។ ការលេងផ្តល់ឱកាស "តាមធម្មជាតិ" ជាច្រើនដល់កុមារដើម្បីធ្វើចលនាផ្លាស់ប្តូរទីតាំង និងរៀនសូត្រ។



**នៅពេលក្មេងម្នាក់ឃើញវត្ថុគួរឱ្យចាប់អារម្មណ៍ នាងឈោងយកវា ឬ វារទៅរកវត្ថុនោះ។ ប្រការនេះជួយដៃ និងជើងរបស់នាងឱ្យលូតលាស់រឹងមាំ។**



**ការលេងជាមួយវត្ថុជួយក្មេងរៀនអំពីបំណិនការគិត ដូចជាការដោះស្រាយបញ្ហាងាយៗ។ នៅត្រង់នេះក្មេងកំពុងរៀនរបៀបឈោងយកប្រដាប់លេងមកជិតខ្លួនដោយទាញខ្សែរបស់វា។**




**ការលេងក៏ជួយកុមារឱ្យចេះនិយាយ។ នៅពេលនាងកំពុងចាប់អារម្មណ៍នឹងវត្ថុ នាងរៀនដាក់ឈ្មោះឱ្យវត្ថុទាំងនោះ។**

តាមធម្មតាកុមារធ្វើត្រាប់តាមនូវអ្វីដែលពួកគេមើលឃើញ។ ការមើលទៅមនុស្សដទៃជួយកុមាររៀនពីរបៀបធ្វើអ្វីៗ និងរបៀបសម្របខ្លួន។



**កុមារតូចរៀននិយាយដោយការស្តាប់ឮមនុស្សឯទៀតនិយាយគ្នា និងដោយការមើលឃើញពីអ្វីដែលមនុស្សទាំងនោះនិយាយ។**



**កុមាររៀនរបៀបស្លៀកពាក់ខ្លួនឯងដោយការមើលទៅមនុស្សឯទៀត។**

កុមារដែលមិនអាចមើលឃើញច្បាស់មានឱកាស "ធម្មជាតិ" កាន់តែតិចដើម្បីរៀនសូត្រ។ ដូច្នេះគេអាចរៀនបំណិនទាំងឡាយយឺតជាងកុមារដែលមើលឃើញ ហើយការអភិវឌ្ឍរបស់គេអាចចាប់ផ្តើមតាមក្រោយដែរ។



**ទារកដែលមិនអាចមើលឃើញច្បាស់ ជារឿយៗលេងកំសាន្តតិចតួច ពីព្រោះពួកគេមើលមិនឃើញអ្វីដើម្បីលេងជាមួយ។**



**ទារកនេះមិនអាចងើបក្បាលឱ្យនឹងបាន។ ប្រការនេះបានកើតឡើង ពីព្រោះគេមិនបានធ្វើចលនាផ្លាស់ប្តូរទីតាំង និងលេងកំសាន្ត ដូច្នេះសាច់ដុំករបស់គេមិនបានលូតរឹងមាំឡើយ។**

ការចូលរួមក្នុងសង្គមរបស់គេក៏អាចចាប់ផ្តើមយឺតផងដែរ។




**កុមារដែលមិនអាចមើលឃើញច្បាស់អាចមិនយល់ ឬ មិនបានចូលរួមចំណែកនៅក្នុងការជជែកលេង ពីព្រោះគេមិនអាចឃើញអ្វីដែលមនុស្សកំពុងនិយាយសំដៅនោះទេ។**



**ដូច្នេះគេអាចចាប់ផ្តើមចំណាយពេលម្នាក់ឯងកាន់តែច្រើន ពីព្រោះគេមិនយល់នូវអ្វីដែលមនុស្សម្នាកំពុងនិយាយ។**

បញ្ហាភាគច្រើនទាំងនេះមិនចាំបាច់ឱ្យកើតឡើងនោះទេ។ ក្មេងដែលមិនអាចមើលឃើញអាចរៀនប្រើប្រាស់វិញ្ញាណដទៃទៀតដូចជា វិញ្ញាណស្តាប់, ប៉ះ/ស្ទាប, ហិតក្លិន, និងភ្លក់រសជាតិ ដើម្បីជួយពួកគេឱ្យយល់ដឹងពីអ្វីៗដែលនៅជុំវិញខ្លួនគេ និងដើម្បីរៀនអ្វីដែលក្មេងដទៃរៀនតាមធម្មតាដោយការមើលឃើញ។

# របៀបដែលអ្នកអាចជួយកុមារ

ការជួយកុមារតូចៗឱ្យអភិវឌ្ឍគ្រប់ផ្នែកនៃរាងកាយ និងគំនិតរបស់ពួកគេតាមរយៈឱកាសដែលបានគ្រោងទុកដើម្បីបង្កឱ្យមានបទពិសោធន៍ស្ទាបស្ទង់រាវរក និងលេងកំសាន្តជាមួយរបស់របរគឺហៅថា "ការរំញោចឱ្យដឹង" ឬ "ការជួយទាន់អាយុនៅតិច" ។ នៅក្នុងសៀវភៅនេះ អ្នកនឹងរកឃើញសកម្មភាពសាមញ្ញៗជាច្រើនដែលអាចធ្វើបាន ខណៈដែលអ្នកលេងកំសាន្តជាមួយកូន ឬ ខណៈដែលអ្នកធ្វើកិច្ចការប្រចាំថ្ងៃ ។ អ្នកក៏អាចយកសកម្មភាពសាមញ្ញៗទាំងនោះមកដាក់បញ្ជ្រាបឱ្យសមស្របនឹងកូនរបស់អ្នក ព្រមទាំងជីវិតរស់នៅប្រចាំថ្ងៃរបស់អ្នកផងដែរ ។ ឧទាហរណ៍ :-




**បើអ្នកទាក់ទាញចំណាប់អារម្មណ៍ពីទារករបស់អ្នកដោយសម្លេងនៃប្រដាប់លេង ហើយបង្ហាញសម្លេងដែលវត្ថុនោះបញ្ចេញ...**




**... កូនកាន់តែចាប់អារម្មណ៍នឹងការលេង។ កូននឹងរៀនផ្តោតការយកចិត្តទុកដាក់ទៅសម្លេង និងទីកន្លែងដែលសម្លេងនោះបន្លឺចេញមក។**

---




**បើអ្នកលើកទឹកចិត្តកូនឱ្យចេះប្រើវិញ្ញាណនៃការស្ទាប ការស្តាប់ និងហិតក្លិនដើម្បីស្វែងរកឱ្យឃើញវត្ថុមានរាងរៅយ៉ាងម៉េចខ្លះ...**




**...កូននឹងរៀនកាន់តែច្រើនអំពីព្រឹត្តិការណ៍ទាំងឡាយ ហើយអាចមានលទ្ធភាពនិយាយអំពីអ្វីដែលគេដឹង។**

បើសិនជាអ្នកអនុវត្តសកម្មភាពប្រភេទនេះឱ្យបានញឹកញាប់ នោះវ័យកុមារភាពរបស់កូនអ្នកនឹងពោរពេញទៅដោយភាពរីករាយ និងការរៀនចេះដឹងដូចកុមារដទៃអញ្ចឹងដែរ ។ នៅពេលគេធំឡើងគេអាចរៀនដើម្បី :-




**បំលាស់ទីតាំងដោយខ្លួនឯង**




**លេងជាមួយកុមារដទៃ**




**ជួយធ្វើកិច្ចការរបស់ក្រុមគ្រួសារ**




**ទៅសាលារៀន ឬ រៀនអំពីការមុខរបរចិញ្ចឹមជីវិត**

## តើអនាគតកូនខ្ញុំយ៉ាងដូចម្តេចទៅ?

ឪពុកម្តាយជាច្រើនរូបតែងព្រួយចិត្តអំពីអនាគតរបស់កូនខ្លួន ទោះបីជាក្រោយពេលដែលកូនរៀនបំណិនថ្មី និងទៅសាលារៀនហើយក៏ដោយ ។ ពួកគាត់មានមន្ទិលសង្ស័យថា "នៅពេលគេធំឡើង តើមានអ្វីកើតឡើងទៅ? តើគេគ្រប់គ្រងខ្លួនយ៉ាងណានៅពេលដែលអត់ពីយើងទៅ?

ជួនកាលការរៀនអំពីអ្នកដទៃអាចជួយដល់ឪពុកម្តាយ ទោះបីជាបុគ្គលនោះមិនអាចមើលឃើញក៏ដោយ នៅពេលគេធំពេញវ័យ គេឈានទៅរកជីវិតរស់នៅពេញលេញ និងគាប់ប្រសើរក្នុងចិត្ត – គេមានគ្រួសារផ្ទាល់ខ្លួន – ចេះរកប្រាក់ចំណូលគាំទ្រការរស់នៅ និងក្លាយជាសមាជិកដែលគួរឱ្យគោរពស្រឡាញ់ពីសហគមន៍នានារបស់គេ។ ជនពិការភ្នែកអាចទទួលបានជោគជ័យបែបនេះ នៅពេលដែល :-

- មនុស្សម្នាមានការយល់ដឹងថា កុមារពិការភ្នែកគឺអាចរៀនសូត្របានដូចកុមារដទៃគ្រប់រូបអញ្ចឹងដែរ។
- ក្រុមគ្រួសារ និងសហគមន៍របស់គេជួយជ្រោមជ្រែងពួកគេឱ្យទទួលបានជោគជ័យ។

នេះជាឧទាហរណ៍ :- វាគឺជាផ្លូវអនាគតសំរាប់**រ៉ានី** :-

នៅពេល**រ៉ានី**ធំឡើង ជាញឹកញាប់នាងតែងជួយការងារឪពុកម្តាយនៅក្នុងហាងរបស់ពួកគាត់។ **រ៉ានី**ពូកែគិតលេខណាស់ នាងអាចមានសមត្ថភាពជួយកិច្ចការគណនេយ្យនៅក្នុងហាង នៅពេលនាងបញ្ចប់ការសិក្សានៅសាលារៀន។ នាងក៏អាចកត់បញ្ជីមុខទំនិញដោយអក្សរប្រៃយ៍ផងដែរ។ ឪពុកម្តាយ**រ៉ានី**សប្បាយចិត្តចំពោះជោគជ័យជាស្ថាពររបស់នាង។

នៅពេល**រ៉ានី**អាយុបាន 18 ឆ្នាំ ឪពុកម្តាយនាងបានយល់ព្រមចំពោះការស្នើសុំរៀបការពី**ម៉ានី** បុរសវ័យក្មេងនៅក្នុងភូមិជាមួយគ្នា។ **ម៉ានី**និង**រ៉ានី**បានរៀបការហើយ ហើយក្រោយពេល**រ៉ានី**មានកូនដំបូង នាងទុកកូននៅក្បែរខ្លួនពេលនាងធ្វើការនៅក្នុងហាង។ **រ៉ានី**មានសមត្ថភាពយ៉ាងពេញលេញ ដែលធ្វើឱ្យមនុស្សម្នាចាប់ផ្តើមមកពឹងពាក់លើការប៉ិនប្រសប់របស់នាងតាមវិធីផ្សេងៗទៀត។







ក្មេងៗបានស្នើឱ្យនាងជួយកិច្ចការសាលារៀនរបស់ពួកគេ។ "ជាទូទៅ**រ៉ានី**បានដឹងចម្លើយជាស្រេច" ពួកគេនិយាយ។ ហើយនៅពេលស្ត្រីមួយចំនួននៅក្នុងភូមិចាប់ផ្តើមសិប្បកម្មតម្បាញ ពួកគេមករក**រ៉ានី**ឱ្យជួយបង្កើតគណនេយ្យឱ្យពួកគេ។

ពេលខ្លះ**រ៉ានី**សញ្ជឹងគិតអំពីជីវិតរបស់នាង ថាតើវាអាចខុសគ្នាបែបណាបើសិនជានាងអាចមើលឃើញ។ "ខ្ញុំប្រហែលជាធ្វើបានតិចជាងនេះ បើសិនជាខ្ញុំភ្នែកភ្លឺ" នាងនិយាយ "ជាមនុស្សពិការភ្នែកបានធ្វើឱ្យខ្ញុំប្តេជ្ញាដើម្បីមានជីវិតរស់នៅដូចមនុស្សដទៃទៀតអញ្ចឹងដែរ"។